**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 03-May-2019, 12:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញលើសេចក្ដីសម្រេចស្ដីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Cécile ROUBEIX
កញ្ញា Marine BOUDJEMAA
កញ្ញា Dounia HATTABI
កញ្ញា ស៊ូស៊ីន ច័ន្ទចរិយា

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល បានចេញ "សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ" ("សេចក្តីសម្រេច")[1]។ លោក នួន ជា បានស្នើសុំពេលវេលាប្រាំមួយខែ និងចំនួន ១០០ ទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[2]។ លោក ខៀវ សំផន បានស្នើសុំពេលវេលាប្រាំបីខែ និងចំនួន ១០០ ទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[3]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតផ្តល់ជូនពេលវេលាបីខែ និងចំនួន ៦០ ទំព័រដល់គ្រប់ភាគី[4]។

២. តាមរយៈសារណានេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ("ក្រុមមេធាវីការពារក្តី") ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តាពិនិត្យលើសេចក្តីសម្រេចឡើងវិញ។

៣. អង្គជំនុំជម្រះទាំងអស់មានអំណាចឆន្ទានុសិទ្ធិក្នុងការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន មិនត្រឹមតែដោយសារហេតុផលនៃការវិវត្តនៃកាលៈទេសៈប៉ុណ្ណោះទេ តែក៏អាចធ្វើទៅបានផងដែរ ខណៈដែលសេចក្តីសម្រេចនោះ ហាក់ដូចជាមិនត្រឹមត្រូវ ឬបង្កឲ្យមានអំពើអយុត្តិធម៌ណាមួយ។ ការវិវត្តនៃកាលៈទេសៈអាចរួមបញ្ចូលផងដែរនូវអង្គហេតុ ឬអំណះអំណាងថ្មីៗ។ អំណាចឆន្ទានុសិទ្ធិនេះពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់អង្គភាពតុលាការ ក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយដោយបិទផ្លូវតវ៉ា។ ភាគីដែលស្នើសុំពិនិត្យសេចក្តីសម្រេចណាមួយឡើងវិញ

---

[1] សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និង ចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F43** ("សេចក្តីសម្រេច")។

[2] សេចក្តីសម្រេច កថាខណ្ឌ ៣។

[3] សេចក្តីសម្រេច កថាខណ្ឌ ៣។ សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1** ("សំណើ") កថាខណ្ឌ ៤២ និង ៤៤។

[4] សេចក្តីសម្រេច កថាខណ្ឌ ១១ និង ១៣។

ត្រូវបង្ហាញថា សំអាងហេតុនៅក្នុងសេចក្ដីសម្រេចដែលរងបណ្ដឹងឧទ្ធរណ៍មានកំហុសជាក់ស្ដែង ឬបង្ហាញថា ការពិនិត្យឡើងវិញមានភាពចាំបាច់ដើម្បីបញ្ចៀសអំពើអយុត្តិធម៌ណាមួយ[5]។

៤. នៅក្នុងករណីនេះ **(I)** សេចក្ដីសម្រេចមានកំហុសយ៉ាងច្បាស់ក្រឡែត ហើយ **(II)** ការពិនិត្យឡើងវិញលើសេចក្ដីសម្រេចមានភាពចាំបាច់ដើម្បីបញ្ចៀសអំពើអយុត្តិធម៌។

## I. <u>សំអាងហេតុនៅក្នុងសេចក្ដីសម្រេចពិតជាមានកំហុសយ៉ាងជាក់ច្បាស់</u>

៥. ជាដំបូង នៅពេលអានសេចក្ដីសង្ខេបនៃសេចក្ដីសន្និដ្ឋានរបស់ភាគីនៅក្នុងសេចក្ដីសម្រេច វាហាក់បីដូចជាអង្គជំនុំជម្រះតុលាការកំពូលមិនបានរាប់បញ្ចូលសេចក្ដីសន្និដ្ឋានទាំងស្រុងរបស់លោក ខៀវ សំផន ឡើយ។ ពិតហើយថាអង្គជំនុំជម្រះតុលាការកំពូលបានអានសំណើបឋមរបស់គាត់ ដោយផ្នែកៗ[6] តែអង្គជំនុំជម្រះតុលាការកំពូលបានមើលរំលងជាពិសេសចម្លើយតប/ចម្លើយទៅកាន់សហព្រះរាជអាជ្ញា[7]។ ជាក់ស្ដែង អង្គជំនុំជម្រះតុលាការកំពូលបានព្យាយាមបន្ថែមមួយកថាខណ្ឌ

---

[5] សេចក្ដីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ **C22/I/68** កថាខណ្ឌ ២៥ និងសម្រង់ពីឯកសារយោងទៅយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ជាពិសេស នៅក្នុងសេចក្ដីសម្រេចដែលបានចេញនៅក្នុងរឿងក្ដី *Galić* ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ដោយលោកស្រីចៅក្រម Florence Ndepele MWACHANDE-MUMBA)។ ចំពោះឧទាហរណ៍នៃយុត្តិសាស្ត្រនៅក្នុងពេលថ្មីៗនេះ សូមមើល៖ រឿងក្ដីរដ្ឋអាជ្ញា *តទល់នឹង Mladić Mladić* ឯកសារ MICT-13-56-A សំណៅសាធារណៈដែលត្រូវកោសលុប “សេចក្ដីសម្រេចលើសំណើសុំពិនិត្យឡើងវិញលើសេចក្ដីសម្រេចដែលត្រូវបានចេញ បន្ទាប់ពីមានសំណើសុំឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន និងដើម្បីធ្វើសេចក្ដីបញ្ជាក់លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចនោះ” ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ទំព័រ ៤។

[6] សេចក្ដីសម្រេច កថាខណ្ឌ ៣៖ ពេលសង្ខេបទឡ្ហីករណ៍ដែលលោក នួន ជា និង លោក ខៀវ សំផន បានលើកឡើង តុលាការកំពូលបានភ្លេចរៀបរាប់ពីទឡ្ហីករណ៍របស់លោក ខៀវ សំផន អំពីការរៀបចំបណ្ដឹងផិតចិត្ត (សំណើ កថាខណ្ឌ ៣៥) ដែលមិនត្រូវបានដោះស្រាយនៅក្នុងសេចក្ដីសម្រេចទេ។ ម៉្យាងវិញទៀត តុលាការកំពូលបានសន្មតថា ទឡ្ហីករណ៍ (សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ និងបញ្ហាគតិយុត្តិថ្មីប្លែក) ថាជាគំនិតរបស់លោក នួន ជា តែម្នាក់ ខណៈដែលលោក ខៀវ សំផន ក៏បានលើកឡើងពីចំណុចនេះដែរ (សំណើ កថាខណ្ឌ ១៨) ។

[7] ការឆ្លើយតប និងចម្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញាស្ដីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F41/1** (ការឆ្លើយតប និងចម្លើយតបទៅនឹង

ទៅលើចម្លើយតបរបស់លោក ខៀវ សំផន ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់មុនពេលចេញសេចក្តីសម្រេច[8] ប៉ុន្តែមិនមានកថាខណ្ឌណាមួយដែលនិយាយដល់សេចក្តីសង្ខេបនៃចម្លើយតប/ចម្លើយទៅកាន់សហព្រះរាជអាជ្ញានោះឡើយ តែឯកសារនោះ បានដាក់ពីរថ្ងៃមុននោះ ពោលគឺបីថ្ងៃមុនពេលចេញសេចក្តីសម្រេច។

៦. បន្ទាប់មក "សំអាងហេតុ" ដ៏ខ្លីបំផុតនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល គឺផ្ទុយទៅនឹងយុត្តិសាស្ត្ររបស់ខ្លួន ដែលបានរំឭកជាអាទិ៍នៅក្នុងការឆ្លើយតប/ចម្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា។ ជាក់ស្តែង បន្ទាប់ពីបានរៀបរាប់ហេតុផលជាច្រើនបញ្ជាក់ពីការបន្ថែមពេលវេលាដ៏ច្រើនសន្ធឹកសន្ធាប់[9] អង្គជំនុំជម្រះតុលាការកំពូលប្រើពាក្យតែមួយឃ្លា "ច្រើនហួសហេតុពេក" ដើម្បីវាយតម្លៃសំណើសុំពេលវេលារបស់ក្រុមមេធាវីការពារក្តី[10] **ដោយមិនបានពន្យល់ពីហេតុផល**។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបន្ថែម "ជាលក្ខណៈទូទៅ" ចំនួន ២ ខែ និង ៣០ ទំព័រ គឺគ្រប់គ្រាន់ហើយ "សម្រាប់គ្រប់ភាគី"[11] **ដោយឥតមានពន្យល់ថាហេតុអ្វីបានជាគ្រប់ភាគីគួរតែមានថិរវេលាដូចៗគ្នា និងចំនួនទំព័រស្មើៗគ្នា ខណៈដែលភាគីនីមួយៗមានតម្រូវការមិនដូចគ្នា**។ ចំណុចទាំងអស់នោះរឹតតែពិបាកយល់ យោងតាមគោលការណ៍ដែលបានរំឭកដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ ដែលលើកឡើងថា ការបន្ថែមពេលវេលានិងចំនួនទំព័រត្រូវតែ**សមាមាត្រ**ទៅតាមទំហំនៃបណ្តឹងសាទុក្ខ[12]។ ផ្អែកតាមគោលការណ៍នេះ ការបន្ថែមពេលវេលានិងចំនួនទំព័រដែលក្រុមមេធាវីការពារក្តីត្រូវទទួលបាន ត្រូវ

---

សហព្រះរាជអាជ្ញា) ជូនដំណឹងនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៩ ។ គ្មានទទ្បីករណ៍ណាមួយនៅក្នុងការឆ្លើយតប និងចម្លើយតប ត្រូវបានដោះស្រាយនៅក្នុងសេចក្តីសម្រេចទេ។

[8] សេចក្តីសម្រេច កថាខណ្ឌ ៦ ដែលនៅក្នុងនោះ ក៏មានបញ្ជាក់ផងដែរថា លោក ខៀវ សំផន ភាគច្រើន "បានលើកឡើងបញ្ហាដដែលដែល [តុលាការកំពូល] បានសម្រេចរួចរាល់ហើយ"។ នៅទីនេះ នេះគ្រាន់តែជាការពិនិត្យទទ្បីករណ៍នៅក្នុងសំណើដំបូងតែប៉ុណ្ណោះ មិនមែនជាការពិនិត្យទទ្បីករណ៍ដែលត្រូវបានលើកឡើងនៅក្នុងការឆ្លើយតប/ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញានោះឡើយ។

[9] សេចក្តីសម្រេច កថាខណ្ឌ ៨ និង ៩។

[10] សេចក្តីសម្រេច កថាខណ្ឌ ១០។

[11] សេចក្តីសម្រេច កថាខណ្ឌ ១១។

[12] ការឆ្លើយតប/ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ២១ និងការយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៣១ និង ៣២។

**តែមានរយៈពេលវែងសម្បើមក្នុងសំណុំរឿង ០០២/០២ ជាងនៅក្នុងសំណុំរឿង ០០២/០១ និងមានទំហំធំសម្បើមជាងសហព្រះរាជអាជ្ញា**[13]។

៧. ម៉្យាងវិញទៀត ផ្នែកនៃសេចក្តីសម្រេចដែលអង្គជំនុំជម្រះតុលាការកំពូលអធិប្បាយច្រើនស្តីពីការបកប្រែជាភាសាខ្មែរ[14] ក៏មានកំហុសដែរ។ ការអះអាងថាមានការអនុវត្តជាទូទៅ នៅ អ.វ.ត.ក ដោយឯកសារក្នុងបរិមាណដ៏ក្រាស់ក្រែលត្រូវបញ្ជូនទៅអង្គភាពបកប្រែភាសាជាបន្តបន្ទាប់ គឺជាការអះអាងគ្មានមូលដ្ឋាន និងមិនត្រឹមត្រូវ។ ជាក់ស្តែង ករណីឯកសារក្រាសៗជាច្រើនទំព័រនៅក្នុងឯកសារស៊ើបសួរ[15] មិនអនុវត្តតាមបែបនោះឡើយ។ ករណីសារណាបញ្ចប់ នៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២[16] រួមទាំងសេចក្តីសន្និដ្ឋានស្ថាពរនៃបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០២/០១ ក៏មិនបានអនុវត្តតាមបែបនោះដែរ[17]។

៨. ចំណុចចុងក្រោយ ទោះបីជាអង្គជំនុំជម្រះតុលាកាកំពូលពុំបានធ្វើការពិចារណា ដូចដែលខ្លួនបានធ្វើនៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងនឹងកាលៈទេសៈពិសេសនៃការបកប្រែនៅ អ.វ.ត.ក ដើម្បីផ្តល់ពេលវេលាច្រើនជាងនៅតាមតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាក៏ដោយ[18] ក៏អង្គជំនុំជម្រះតុលាការកំពូលពុំបាននិយាយអ្វីសោះទាក់ទិននឹងកាលៈទេសៈពិសេសមួយផ្សេងទៀតដែលថា នៅ

[13] ការឆ្លើយតប/ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ ២០-២២។

[14] សេចក្តីសម្រេច កថាខណ្ឌ ១១។

[15] ដីកាសន្និដ្ឋានស្ថាពរ ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ដីកាដំណោះស្រាយ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចម្លើយតប និងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះ។ សូមមើល គម្រោងបញ្ចប់ផែនការ ដែលនៅក្នុងនោះ គេយល់ថា ឯកសារត្រូវបានដាក់ដំបូងតែមួយភាសា **បន្ទាប់មក** បកប្រែ។ ជាឧទាហរណ៍៖ កំណែលើកទី ១៧ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១៩ និងកំណត់សម្គាល់ជើងទំព័រ ៧ កថាខណ្ឌ ២០(ក) និង(គ), កំណែលើកទី ២០ ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ ២០១៩ កថាខណ្ឌ ១០(ក) និង (ខ) កថាខណ្ឌ ២៦ (ក) និង (ខ)។

[16] សារណាបញ្ចប់ការពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នៅសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ **E449/1** កថាខណ្ឌ ១០ “ដូចគ្នាទៅនឹងសំណុំរឿង ០០២/០១ ដែរ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលអាចដាក់តែមួយភាសាបាន”។

[17] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ក៏ដូចជាសារណាបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តី ត្រូវបានដាក់តែមួយភាសាលើកដំបូង។

[18] សំណើសុំ កថាខណ្ឌ ១៨ និងការយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ២៦។

អ.វ.ត.ក គឺពុំអាចកែប្រែមូលដ្ឋានបណ្តឹងសាទុក្ខបានឡើយ ក្រោយពីការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខចប់រួចរាល់[19]។

៩. ទោះជាយ៉ាងនេះក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលនៅតែផ្តល់ឱ្យលោក នួន ជា និងលោក ខៀវ សំផន នូវពេលវេលាតិចជាងផ្តល់ឱ្យជនជាប់ចោទមួយចំនួននៅតាមតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ជាមួយនឹងសាលក្រមដែលមានកម្រាស់ប្រហាក់ប្រហែលគ្នា។ "ដើម្បីផលប្រយោជន៍យុត្តិធម៌" ពួកគេទទួលបានរយៈពេល ៤ ខែ ដើម្បីរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែល "សមទៅនឹងឈ្មោះនេះ"[20]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់រយៈពេលដូចគ្នាឱ្យទៅខាងសហព្រះរាជអាជ្ញា ខណៈដែលវិសាលភាពបណ្តឹងសាទុក្ខរបស់ពួកគេមានទំហំតូច ធៀបទៅនឹងវិសាលភាពបណ្តឹងសាទុក្ខរបស់លោក នួន ជា និងលោក ខៀវ សំផន។ ដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល មិនត្រឹមតែមានកំហុសប៉ុណ្ណោះទេ តែវាថែមទាំងអយុត្តិធម៌ និងអសមភាពយ៉ាងខ្លាំងបំផុត។

---

[19] សំណើសុំ កថាខណ្ឌ ៧-៩, ១៨។ លើសពីនេះទៀត តុលាការកំពូលក៏មិនបានលើកឡើង ដូចដែលខ្លួនធ្លាប់បានធ្វើនៅក្នុងសំណុំរឿង ០០២/០១ នូវសេចក្តីសម្រេចបន្ទាន់បន្ទំនានា ដែលជាធាតុផ្សំនៃភាពខុសគ្នាផ្នែកនីតិវិធីមួយផ្សេងទៀតនៅ អ.វ.ត.ក៖ សំណើសុំ កថាខណ្ឌ ១៨ ការឆ្លើយតបទៅនឹងចម្លើយ/ចម្លើយតប កថាខណ្ឌ ១០។

[20] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Ratko Mladić*, MICT-13-56-A សេចក្តីសម្រេចលើសំណើសុំពន្យារពេលវេលាដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ (សូមមើលជាអាទិ៍ ទំព័រ ២៖ "ដើម្បីផលប្រយោជន៍យុត្តិធម៌ គឺត្រូវធ្វើយ៉ាងណាឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ សមទៅនឹងឈ្មោះនេះ ដោយត្រូវគោរពឱ្យបានទាំងស្រុងនូវបទបញ្ញត្តិនានាជាធរមាន"), រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Radovan Karadžić*, MICT-13-55-A សេចក្តីសម្រេចលើសំណើជាថ្មី សុំពន្យារពេលវេលាដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ (សូមមើលជាអាទិ៍ ទំព័រ ៤៖ "ដោយហេតុថាការរៀបចំសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ គឺជាការកំណត់នូវក្របខណ្ឌដែលរាល់បណ្តឹងសាទុក្ខនឹងត្រូវយកមកពិនិត្យ ហើយដើម្បីផលប្រយោជន៍យុត្តិធម៌ គឺត្រូវធ្វើយ៉ាងណាឱ្យ Radovan Karadžić មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ សមទៅនឹងឈ្មោះនេះ ដោយត្រូវគោរពឱ្យបានទាំងស្រុងនូវបទបញ្ញត្តិនានាជាធរមាន"។ ក្នុងរឿងក្តី *Mladić* សាលក្រមមានកម្រាស់ ២ ៥៤១ ទំព័រ រួមបញ្ចូលទាំងឧបសម្ព័ន្ធ។ ក្នុងរឿងក្តី *Karadžić* សាលក្រមមានកម្រាស់ ២ ៦០៧ ទំព័រ រួមបញ្ចូលទាំងឧបសម្ព័ន្ធ។ ទោះបីជាសំអាងហេតុនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ មានកម្រាស់ ២ ៨២៨ ទំព័រ ជាភាសាបារាំង (២ ៣៨៧ ជាភាសាអង់គ្លេស) រួមបញ្ចូលទាំងឧបសម្ព័ន្ធ សម្រាប់ជនជាប់ចោទពីររូបក៏ដោយ ក៏គេត្រូវកត់សម្គាល់ថា មានចំនួនទំព័រតិចបំផុតដែលនិយាយតែពីជនជាប់ចោទម្នាក់ៗ។ ៩១ ទំព័រ ជាភាសាបារាំង (៧៨ ទំព័រ ជាភាសាអង់គ្លេស) និយាយពីតួនាទី និងការទទួលខុសត្រូវរបស់លោក នួន ជា ចំណែកឯ ១៣៧ ទំព័រ ជាភាសាបារាំង (៩២ ទំព័រ ជាភាសាអង់គ្លេស) និយាយពីតួនាទី និងការទទួលខុសត្រូវរបស់លោក ខៀវ សំផន។

## II. ការពិចារណាសេចក្តីសម្រេចឡើងវិញ ពិតជាចាំបាច់ដើម្បីបញ្ចៀសភាពអយុត្តិធម៌

១០. សេចក្តីសម្រេចមានឥទ្ធិពលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការការពារក្តី និងធ្វើឲ្យចំណេញដល់សហព្រះរាជអាជ្ញា។ ដោយពិចារណាឃើញថា ការបន្ថែមរយៈពេល ២ ខែ និងការបង្កើនចំនួន ៣០ ទំព័រ បន្ថែមទៀត គឺគ្រប់គ្រាន់សម្រាប់ភាគីទាំងអស់ "អាចអានសាលក្រមដោយត្រឹមត្រូវ" "អាចយល់ដឹងអំពីការសម្រេច" "និង "អាចគូសបញ្ជាក់ដោយសង្ខេបនូវកំហុស"[21] អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ពេលវេលាឲ្យសហព្រះរាជអាជ្ញា ច្រើនជាងអ្វីដែលពួកគេត្រូវការ[22] ហើយទន្ទឹមគ្នានោះ អង្គជំនុំជម្រះតុលាការកំពូលពុំបានអនុញ្ញាតឲ្យមេធាវីការក្តីធ្វើការងារខ្លួនឲ្យបានត្រឹមត្រូវឡើយ ជាពិសេសការងារ**ស្វែងរក**កំហុសខុសឆ្គង។

១១. សិទ្ធិប្តឹងសាទុក្ខរបស់បុគ្គលដែលត្រូវប្រកាសថាជាប់ពិរុទ្ធពីបទល្មើសណាមួយ ដែលត្រូវបានធានាដោយមាត្រា ១៤-៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាសិទ្ធិ "សុំឲ្យធ្វើការពិនិត្យលើអង្គសេចក្តីនៃការប្រកាសអំពីពិរុទ្ធភាព និងការផ្តន្ទាទោស **ដោយត្រូវពិនិត្យមើលថាតើមានភស្តុតាងគ្រប់គ្រាន់ដែរឬអត់ និងត្រូវយោងទៅតាមបទបញ្ញត្តិគតិយុត្តិជាធរមាន**"[23]។

១២. រយៈពេលជាងមួយខែបន្តិច ក្រោយពីការជូនដំណឹងអំពីសំអាងហេតុនៃសាលក្រម ទាំងលោក ខៀវ សំផន ទាំងមេធាវីការពារក្តីរបស់គាត់ ពិតជាពុំអាចអានចប់សំអាងហេតុទាំងនោះបានទេ។ ការពន្យារពេល ២ ខែ បន្ថែមទៀត (ពោលគឺតិចជាងពាក់កណ្តាលនៃរយៈពេលដែលមេធាវីការពារក្តីស្នើសុំ)[24] នឹងមិនអនុញ្ញាតជាអាទិ៍ឲ្យពិនិត្យ និងផ្ទៀងផ្ទាត់លើប្រភពឯកសារយោងផ្នែកច្បាប់ និងអង្គហេតុ ដែលជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានទាំង ៧៨ ដែលសម្រេចផ្តន្ទាទោសលោក ខៀវ សំផន

---

[21] សេចក្តីសម្រេច កថាខណ្ឌ ១១។

[22] សំណើសុំ កថាខណ្ឌ ៤ (សហព្រះរាជអាជ្ញាស្នើសុំបន្ថែមពេល ៤៥ ថ្ងៃ ដោយពុំស្នើសុំបង្កើនចំនួនទំព័រ)។

[23] រឿងក្តី *Bandajevsky ទល់នឹង Bélarus* សំណុំរឿងលេខ ១១០០/២០០២ សេចក្តីកត់សម្គាល់អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១០.១៣ (យើងជាអ្នកដាក់អក្សរដិត)។

[24] ឬត្រូវជា ៣០ ថ្ងៃ ច្រើនជាងនៅក្នុងសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ (ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ក្នុងរយៈពេល ៥៣ ថ្ងៃ ជាភាសាបារាំង និង ៦០ ថ្ងៃ ជាភាសាខ្មែរ)។

បានទេ ហើយឯកសារយោងទាំងនោះមាននៅក្នុងកំណត់សម្គាល់ជើងទំព័រចំនួន ១៤ ៩៤៦ ដែលមានការយោងយ៉ាងច្រើន។ ម្យ៉ាងវិញទៀត ថ្មីៗនេះ អង្គជំនុំជម្រះបានដាក់សំណើសុំធ្វើការកែតម្រូវសំអាងហេតុនៃសាលក្រម ដើម្បីកែកំហុសមួយចំនួនដែលមាននៅក្នុងការយោង[25] ដែលវាជាសញ្ញាមិនល្អទាល់តែសោះ។ ម្យ៉ាងវិញទៀត បើទោះជាមេធាវីការពារក្តីអាចកំណត់បាននូវភាពខុសគ្នាខ្លះៗរវាងភាសានៃសំអាងហេតុ ទាក់ទិននឹងបញ្ហាចម្បងៗមួយចំនួន នៅដំណាក់កាលនេះក៏ដោយ ក៏ខ្លួននឹងមិនមានពេលវេលាដើម្បីធ្វើការងារនេះបន្តទៀតដែរ។

១៣. មេធាវីការពារក្តីប្រាកដជានឹងមិនអាចលើកឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខឱ្យបានអស់ទេ **ហើយខ្លួនក៏នឹងពុំអាចលើកឡើងនាពេលក្រោយទៅទៀតបានដែរ**។ មេធាវីការពារក្តីក៏នឹងមិនអាចបង្ហាញប្រកបដោយប្រសិទ្ធិភាព នូវមូលដ្ឋានបណ្តឹងសាទុក្ខដែលខ្លួនអាចនឹងកំណត់បាននៅក្នុងឯកសារមួយ ដែលនឹងអាចក្លាយជាឯកសារនាំផ្លូវសម្រាប់មេធាវីការពារក្តីក្នុងការធ្វើសារណាប្តឹងសាទុក្ខ។ គ្មាននរណាម្នាក់ត្រូវតែធ្វើនូវរឿងដែលមិនអាចទៅរួចនោះទេ។

១៤. សេចក្តីសម្រេចមានឥទ្ធិពលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានពេលវេលា និងមធ្យោបាយចាំបាច់នានាដើម្បីរៀបចំការការពារក្តីរបស់គាត់ និងប៉ះពាល់ដល់សិទ្ធិធ្វើបណ្តឹងសាទុក្ខប្រកបដោយភាពជាក់ស្តែង និងប្រសិទ្ធិភាព។ វាក៏ប៉ះពាល់ធ្ងន់ធ្ងរផងដែរទៅដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានភាពស្មើគ្នាក្នុងការតវ៉ាក្តី ដែលតាមរយៈសិទ្ធិនេះ គាត់ត្រូវទទួលបានលទ្ធភាពសមហេតុផល ក្នុងការបង្ហាញរឿងក្តីរបស់គាត់ នៅក្នុងល័ក្ខខ័ណ្ឌដែលមិនដាក់ឲ្យគាត់ស្ថិតក្នុងស្ថានភាពចាញ់ប្រៀបគូប្រកួតរបស់គាត់ឡើយ[26]។ អង្គជំនុំជម្រះតុលាការ

[25] សំណើសុំកែតម្រូវលើឯកសារ E465 ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **E465/Corr-1** ជូនដំណឹងនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

[26] ឧទាហរណ៍ សូមមើល តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Bulut ទល់នឹង Autriche* (សំណើលេខ ១៧៣៥៨/៩០) សាលដីកាចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៦ កថាខណ្ឌ ៤៧៖ "តុលាការសូមរំលឹកថា យោងតាមគោលការណ៍សមភាពនៃការតវ៉ាក្តី ដែលជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយនៃសញ្ញាណទូលំទូលាយនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ភាគីនីមួយៗត្រូវទទួលបានលទ្ធភាពសមហេតុផល ក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌដែលមិនដាក់ឲ្យគាត់ស្ថិតក្នុងស្ថានភាពចាញ់ប្រៀបគូប្រកួតរបស់ខ្លួនឡើយ។ ក្នុងបរិបទនេះ តុលាការផ្តល់សារៈសំខាន់ដល់រូបភាពខាងក្រៅ ដូចគ្នាទៅនឹងការបារម្ភដែលមានការកើនឡើងទាក់ទិននឹងការធានាឲ្យបាននូវយុត្តិធម៌ត្រឹមត្រូវ" (ដកឯកសារយោងចេញ)។

កំពូលត្រូវពិនិត្យសេចក្តីសម្រេចឡើងវិញ ដើម្បីចៀសវាងភាពអយុត្តិធម៌ធ្ងន់ធ្ងរ និងព្យសនកម្មដែលមិនអាចជួសជុលបាន។

១៥. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តា**ពិនិត្យឡើងវិញ**នូវសេចក្តីសម្រេចរបស់ខ្លួន ដោយត្រូវពិចារណាលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានទាំងមូលរបស់លោក ខៀវ សំផន និងស្នើសុំឲ្យតុលាការកំពូល**សម្រេចតាម**សំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័ររបស់លោក ខៀវ សំផន។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br>ទីក្រុងប៉ារីស | |